គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០១៤

# សេចក្តីប្រកាសអត្ថបទ

## ស្តីពី

## ការបង្កើតថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមភាគតិចនៅរដ្ឋសភា

ក្រុមភាគតិចនៅរដ្ឋសភាអាចត្រូវបាននិយាយថា ក្រុមគណបក្សប្រឆាំងនៅរដ្ឋសភាឬ (ក្រុម)គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ នៅកម្ពុជាអ្នកនយោបាយភាគច្រើន មិនចង់ឲ្យប្រើពាក្យ «គណបក្សប្រឆាំងនៅរដ្ឋសភា» ដូចនេះហើយនៅក្នុង កិច្ចព្រមព្រៀងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងវិសោធនកម្មជំពូកទី១៥ថ្មី នៃរដ្ឋធម្មនុញ្ញ មានការប្រើពាក្យថា «គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល»។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្រាប់តែមេដឹកនាំគណបក្សទាំងពីរបានជ្រើសរើសពាក្យថ្មីមួយទៀត គឺ«ក្រុមភាគតិចនៅរដ្ឋសភា»។ ប្រការ០៤ នៃកិច្ចព្រមព្រៀងថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៤ នៃថ្នាក់ដឹកនាំគណបក្សទាំងពីរបានបញ្ជាក់ថា «លើកកម្ពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែល មិនចូលក្នុងរាជរដ្ឋាភិបាល»។ ក្រុមភាគតិចនៅរដ្ឋសភាអាចក្លាយជាបញ្ញត្តិថ្មី។ មានការពន្យល់ថា ប្រធានក្រុមភាគតិចនៅរដ្ឋសភាគឺយកគំរូតាមរដ្ឋសភាសហរដ្ឋអាមេរិក។ ប្រទេសសហរដ្ឋអាមេរិកគឺប្រកាន់របបប្រធានាធិបតីនិយម ដែលមិនដូចប្រទេសកម្ពុជាជារបបសភានិយម។ ប្រទេសសហរដ្ឋអាមេរិកមានប្រធានក្រុមភាគតិច និងក្រុមច្រើននៅរដ្ឋសភាផងដែរ។ ជាគោលការណ៍ប្រធានក្រុមភាគតិច និងប្រធានក្រុមភាគច្រើនតែងតែជួបគ្នាប្រជុំពិភាក្សាអំពីបញ្ហាធំ ចម្រូងចម្រះរបស់ជាតិ ពេលខ្លះក៏មានការសន្ទនារួមរវាងប្រធានក្រុមភាគតិច ប្រធានក្រុមភាគច្រើននៅរដ្ឋសភា ជាមួយនឹងប្រធានាធិបតី។ ក្នុងន័យនេះ នៅប្រទេសកម្ពុជា ប្រធានក្រុមភាគច្រើន គឺជានរណា? គណបក្សដឹកនាំរដ្ឋាភិបាល ឬគណបក្សកាន់អំណាចប្រហែល និយាយទៅដល់លោកនាយករដ្ឋមន្ត្រី ព្រោះថានាយករដ្ឋមន្ត្រីនៃគណបក្សប្រជាជនកម្ពុជាបានការទុកចិត្តភាគច្រើនពីគណបក្សមានអាសនៈភាគច្រើននៅរដ្ឋសភា ព្រោះថាកិច្ចព្រមព្រៀងគណបក្សទាំងពីរនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤បានបញ្ជាក់ថាមានការសន្ទនារវាងនាយរដ្ឋមន្ត្រី និងប្រធានក្រុមភាគតិចក្នុងរដ្ឋសភាអំពីបញ្ហាប្រទេសជាតិ។ ត្រង់នេះប្រធាន ឬអនុប្រធានរដ្ឋសភាមិនមែនតំណាងឲ្យថ្នាក់ដឹកនាំក្រុមភាគតិច ឬក្រុមភាគច្រើនរដ្ឋសភាទេ។ ប្រធាន និងអនុប្រធានរដ្ឋសភាមានតួនាទីដឹកនាំ ឬសម្របសម្រួលការប្រជុំសម្រេច ឬដំណើរការរបស់រដ្ឋសភា។

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

នៅសហរដ្ឋអាមេរិក ប្រធានក្រុមភាគតិច ប្រធានក្រុមភាគច្រើន ឬប្រធានាធិបតិមិនមែនជាមេដឹកនាំនៃគណបក្សរបស់ខ្លួនទេ ចំណែកប្រទេសប្រជាធិបតេយ្យកាន់របបសភានិយម (ចក្រភពអង់គ្លេស និង អូស្ត្រាលី) ពិសេសគំរូ Westminister ទទួលស្គាល់មេដឹកនាំ ឬប្រធាន[ក្រុម]គណបក្សប្រឆាំង ដែលគឺជាប្រធានគណបក្សប្រឆាំងមួយមាន អាសនៈច្រើនជាងគេនៅរដ្ឋសភា។ របបសភានិយមនៃគំរូ Westminister មានមេដឹកនាំក្រុម] គណបក្សប្រឆាំង នាយករដ្ឋមន្ត្រី និងប្រធាន អនុប្រធានរដ្ឋសភា។

ចាប់តាំងពីវិសោធនកម្មជំពូក១៥ ថ្មី នៃរដ្ឋធម្មនុញ្ញ គណបក្សប្រឆាំងនៅកម្ពុជាត្រូវបានទទួលស្គាល់ជាគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមានសិទ្ធិអំណាចស្មើគ្នា នឹងគណបក្សដឹកនាំរាជរដ្ឋាភិបាល ក្នុងការជ្រើសរើសសមាសគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)។ ក្នុងចំណោមសមាសភាពប្រាំបួនរូប សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូបទៀតត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណៈបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា។

រដ្ឋធម្មនុញ្ញមានឋានានុក្រមខ្ពស់ជាងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ពាក្យ «ប្រធានក្រុមភាគតិចនៅរដ្ឋសភា» ដែលគណៈបក្សទាំងពីរនឹងប្រើប្រាស់ក្នុងវិសោធន៍កម្មប្រការ៤៨ថ្មី(ពីរ)នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គឺ មានន័យសំដៅទៅលើប្រធាន(ក្រុម)គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ ដែលបណ្តាប្រទេសប្រកាន់របបសភានិយមមួយចំនួនហៅថាប្រធាន(ក្រុម)គណបក្សប្រឆាំង។ ដូចនេះវាជាការប្រសើរ ក្នុងការប្រើពាក្យ ប្រធាន(ក្រុម) គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ជាជាងប្រើពាក្យប្រធានក្រុមភាគតិចនៅរដ្ឋសភា។ ម្យ៉ាងវិញទៀតការប្រើពាក្យនេះ ដូចគ្នានឹងពាក្យក្នុងមាត្រា ១៥១ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ។ មានការលើកឡើងថាប្រធានក្រុមភាគតិចនៅរដ្ឋសភាត្រូវមានអាសនៈយ៉ាងតិច ២៥% តែប្រទេសឥណ្ឌាថ្នាក់ដឹកនាំគណបក្សប្រឆាំងដែលគណបក្សនោះមានអាសនៈច្រើនជាងគេយ៉ាងតិច ១០%។ បើទោះបីត្រឹម១០% បច្ចុប្បន្នប្រទេសឥណ្ឌាពុំមានមេដឹកនាំគណបក្សប្រឆាំងផ្លូវការផង។

ការរៀបចំឲ្យមានថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា ដូចដែលមានចែងក្នុងលទ្ធផលនៃជំនួបកំពូលរវាងថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ហាក់ដូចជាផ្តល់ការលំបាក និងស្មុគស្មាញ ឬមិនជាក់លាក់ថាគណបក្សដែលទទួលបានអាសនៈតិចជាងប្រាំភាគរយ(០៥%) នៃអាសនៈរដ្ឋសភាទាំងមូល អាចបង្កើតក្រុមតំណាងរាស្ត្ររបស់ខ្លួននៅរដ្ឋសភា។ គណបក្សប្រជាជនកម្ពុជា បានលើកឡើងថា «ប្រធានតំណាងរាស្ត្ររបស់គណបក្សនយោបាយ មានអាសនៈចាប់ពី០៥%ឡើងទៅ (គណបក្សនោះ) អាចចងក្រងជាក្រុមដែលគេហៅថាប្រធានក្រុមតំណាងរាស្ត្រគណបក្សនយោបាយនីមួយៗ......។ ក្នុងចំណោមក្រុមប្រធានតំណាងរាស្ត្រគណបក្សនយោបាយនីមួយៗ ប្រធានក្រុមគណបក្សនយោបាយណាដែលមានអាសនៈយ៉ាងតិច ២៥% នៃរដ្ឋសភា នឹងក្លាយជាប្រធានក្រុមភាគតិច.......»។ លោកនាយកមន្ត្រី ហ៊ុន សែន នៃគណបក្សប្រជាជនកម្ពុជា ក៏បានបញ្ជាក់បន្ថែមកាលពីថ្ងៃទី០៤ ធ្នូ ២០១៤ ដែរថា« ពីមុនមានក្រុមតំណាងរាស្ត្រ ក្នុងមួយក្រុមមាន១០នាក់ សម្រាប់ការពិភាក្សា ប៉ុន្តែនៅមានប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សដែលមានអាសនៈក្នុងសភា... គណបក្សដែលមាន០៥%ឡើងលើត្រូវបង្កើតឲ្យមានក្រុមតំណាងរាស្ត្រទាំងគណបក្សក្នុងរដ្ឋាភិបាល និងបក្សក្រៅរដ្ឋាភិបាល។ មានក្រុមតំណាងមួយដែលមានសម្លេង២៥%ដែលចាត់ទុកថាធំជាគេ គឺជាដៃគូសន្ទនាជាមួយប្រមុខ

ដឹកនាំរាជរដ្ឋាភិបាល»។ ការលើកឡើងខាងលើនេះ បន្ថែមភាពមិនច្បាស់លាស់ថា តើប្រធានក្រុមតំណាងរាស្ត្រគណបក្សនយោបាយត្រូវមានអាសនៈចាប់ពី០៥% និងមានតួនាទីជាអ្វី និងដើម្បីបំពេញសិទ្ធិអំណាចអ្វី? ថាតើប្រធានក្រុមភាគតិច និយាយទៅដល់គណបក្សប្រឆាំង ឬគណបក្សកាន់អំណាចណាក៏ដោយ ឲ្យតែមានអាសនៈយ៉ាងតិច ២៥% ឬក៏សំដៅតែគណបក្សប្រឆាំង ឬគណបក្សមានអាសនៈក្នុងសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល?

ម្យ៉ាងវិញទៀតការកំណត់យកអាសនៈចំនួន ២៥%នៃរដ្ឋសភា នៃគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ជាល័ក្ខខ័ណ្ឌការបង្កើតប្រធានក្រុមភាគតិចនោះ នៅមានភាពមិនច្បាស់លាស់ត្រង់ថាចំនួនអាសនៈ២៥%នោះ ជាអាសនៈនៃគណបក្សតែមួយ ឬអាចជាចំនួនអាសនៈនៃការបូកបញ្ចូលគ្នានៃក្រុមគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល? ព្រោះការតម្រូវចំនួនភាគរយនៃអាសនៈច្រើន បើដូចរដ្ឋសភានៅអាណត្តិកន្លងមកគ្មានទេប្រធានក្រុមភាគតិច។

ការបង្កើតប្រធានក្រុមភាគតិច អាចចូលរួមលើកកម្ពស់តួនាទីគណបក្សប្រឆាំង ឬគណបក្ស មានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងបង្កើនវប្បធម៌សន្ទនារវាងថ្នាក់ដឹកនាំគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា។ ជាការពិតណាស់ តួនាទីរបស់ប្រធានក្រុមភាគតិចនៅរដ្ឋសភា ឬថ្នាក់ដឹកនាំគណបក្សប្រឆាំង មានសិទ្ធិអំណាចក្នុងការដេញដោលក្នុងសភាឈរទល់មុខជាមួយនាយករដ្ឋមន្ត្រី បើយោងតាមគំរូប្រទេសនៃ Westminister។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងជាសាធារណៈ ក្នុងពិធីចែកសញ្ញាបត្រដល់និស្សិត កាលពីថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៤ ថាប្រធានក្រុមភាគតិចឋានៈស្មើនាយករដ្ឋមន្ត្រីនេះ គឺបង្ហាញអំពី អាសនៈក្រមសម្រាប់ការរៀបចំផ្នែកពិធីការ.....[1]។ ដូចនេះពិធីការនៃការពិភាក្សាដេញដោលក្នុងរដ្ឋសភា គួរមានវត្តមាន នាយករដ្ឋមន្ត្រី និងប្រធានក្រុមភាពតិច(នៃគណបក្សប្រឆាំង) អង្គុយ ឬឈរទល់មុខគ្នា។ ម្យ៉ាងទៀតពិធីការក្នុង រដ្ឋសភា នៅពេលនាយករដ្ឋមន្ត្រីថ្លែងសុន្ទរកថាដល់ភ្ញៀវសំខាន់ៗ ក៏ទុកពេលឲ្យប្រធានក្រុមភាគតិច(នៃគណបក្សប្រឆាំង) មានឱកាសថ្លែងសុន្ទរកថាផងដែរ។ ប្រធានក្រុមភាគតិចគួរត្រូវបានអនុញ្ញាតឲ្យបង្កើតអ្នកនាំពាក្យ នៃក្រុមភាគតិចនៅរដ្ឋសភាទទួលបន្ទុកវិស័យសំខាន់របស់រាជរដ្ឋាភិបាល។ ព្រោះថា គណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាលមិនបានដឹកនាំគ្រប់គណៈកម្មការជំនាញនៃរដ្ឋសភា។

វារឿងប្រសើរ ប្រសិនបើនាយករដ្ឋមន្ត្រី ដែលប្រធានក្រុមភាគច្រើននៅរដ្ឋសភា ធ្វើការពិគ្រោះយោបល់ ជាមួយប្រធានក្រុមភាគតិច និងទទួលយកយោបល់នោះទៅពិចារណាមុននឹងធ្វើការសម្រេចចិត្តសំខាន់ៗ ដូចជា ការតែងតាំងថ្នាក់ដឹកនាំស្ថាប័នរដ្ឋសំខាន់ៗដូចជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ជាដើម។ ក្នុងការធ្វើវិសោធនកម្មប្រការ៤៨ថ្មី(ពីរ) គណបក្សទាំងពីរគប្បីព្រមព្រៀងគ្នាលប់ចោលលក្ខខណ្ឌតម្រូវតំណាងរាស្ត្រ១០នាក់ ក្នុងការបង្កើតក្រុម ឬទុកឲ្យមានក្រុមតំណាងរាស្ត្រចំនួន០១ចំពោះគណៈបក្សទទួលបានអាសនៈតិចជាង១០ ដែលផ្ដល់ការបញ្ចេញមតិដល់គណបក្សនោះក្នុងសភាពេញអង្គ។ វិសោធនកម្មបទបញ្ជាផ្ទៃក្នុងគួរដាក់បញ្ចូលគោលការណ៍បែងចែកអំណាចនៅក្នុងរដ្ឋសភាថា គណបក្សដឹកនាំរាជរដ្ឋាភិបាល ទទួលតួនាទីដឹកនាំគណៈកម្មការ មានចំនួនស្មើនឹងចំនួនគណៈកម្មការដឹកនាំដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ ការបែងចែកអំណាចច្បាស់លាស់

---

[1] អត្ថបទ៖ លោកហ៊ុន សែន៖ កម្ពុជាគ្មាននាយករដ្ឋមន្ត្រីពីរនោះទេ, ដោយ៖ វណ្ណ សុគន្ធា, វិទ្យុបារាំងអន្តរជាតិ,ចុះផ្សាយថ្ងៃទី០៤ ធ្នូ ២០១៤

ក្នុងការដឹកនាំគណៈកម្មការជំនាញ រដ្ឋសភា និងការមានប្រធានក្រុមភាគតិច ឬប្រធានក្រុមនៃគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាលច្រើនជាងគេ ជាមួយតួនាទី និងសិទ្ធិអំណាចច្បាស់លាស់អាចនាំមកនូវការអភិវឌ្ឍ នៃលទ្ធិប្រជាធិបតេយ្យក្នុងរបបសភានិយមនៃប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

- លោក គល់ បញ្ញា នាយកប្រតិបត្តិ នៃអង្គការខុមហ្វ្រែល ០១២ ៩៤ ២០ ១៧
- លោក សៀន ប៊ុនរិទ្ធ មន្ត្រីផ្នែកអង្កេត នៃអង្គការខុមហ្វ្រែល ០៨៩ ២១ ២១ ១០

<u>បេសកកម្ម</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។